# វិស័យជលផល និងបញ្ហាប្រឈម

## នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ខែ សីហា ឆ្នាំ២០១១

អនុក្រុមស្រាវជ្រាវសេដ្ឋកិច្ចកសិកម្ម
នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC)

ទីស្តីការគណៈរដ្ឋមន្ត្រី

## មាតិកា


| | ទំព័រ |
|---|---|
| **បញ្ជីតារាង** | iii |
| I. **សេចក្តីផ្តើម** | 1 |
| II. **ស្ថានភាពជលផល** | 2 |
| ១-ជលផលទឹកសាប | 2 |
| ២-ជលផលសមុទ្រ | 5 |
| ៣-វារីវប្បកម្ម | 6 |
| ៤-ជលផលកែច្នៃ | 9 |
| ៥-ការនាំត្រីចេញទៅបរទេស | 10 |
| ៦-សកម្មភាពរបស់រដ្ឋបាលជលផល | 12 |
| ក.បុគ្គលិក | 12 |
| ខ.សកម្មភាពផ្លូវច្បាប់ និងការបង្ក្រាបបទល្មើស | 13 |
| គ.សហាគមន៍នេសាទ | 14 |
| III.**បញ្ហាប្រឈម និងឧបសគ្គ** | 15 |
| ១-ការនេសាទហួសកម្រិត | 15 |
| ២-កំណើនប្រជាពលរដ្ឋ | 15 |
| ៣-ឧបករណ៍ខុសច្បាប់ | 15 |
| ៤-ការបាត់បង់ជម្រករបស់ត្រី | 16 |

៥-វារីអគ្គិសនី 16

៦-កង្វះមន្ទីរពិសោធន៍ 17

៧-កង្វះអ្នកឯកទេស និងបច្ចេកទេស 17

៨-កង្វះការទាក់ទងគ្នារវាងអ្នកប្រកបមុខរបរនេសាទ 17

IV.**ភាពលទ្ធភាព** 18

១-ការបង្ក្រាបបទល្មើស 18

២- បង្កើនចំនួនកន្លែងភ្ញាស់កូនត្រីពូជ 18

៣-ការពង្រឹងសហគមន៍នេសាទ 19

៤-វារីវប្បកម្ម 19

៥-ការពង្រឹងសមត្ថភាពបុគ្គលិករដ្ឋបាលជលផល 19

៦-ការសម្របសម្រួលរបៀបធ្វើជំនួញ 20

៧-បញ្ហាទាក់ទងនឹងដំណើរការក្រោយពីចាប់បានត្រី 20

V.**ភក្តាគម្រោងកំហែង** 21

VI.**អនុសាសន៍** 21

References 22

Meeting 22

# បញ្ជីតារាង

ទំព័រ


តារាង១-អត្រារួមចំណែកជាភាគរយរបស់វិស័យកសិកកម្មក្នុងផលិតផលក្នុងស្រុកសរុបឆ្នាំ ១៩៩៩-២០០៩ 1

តារាង២-អត្រារួមចំណែកជាភាគរយរបស់អនុវិស័យនីមួយៗក្នុងវិស័យកសិកម្មឆ្នាំ ២០០៥-២០០៩ 2

តារាង៣-ផលផលទឹកសាប-សមុទ្រ និងវារីវប្បកម្មឆ្នាំ ២០០៥-២០០៩ (ជា១០០០តោន) 3

តារាង៤-ចំនួនត្រីសមុទ្រដែលចាប់បានតាមខេត្ត ឆ្នាំ ២០០៥-២០០៩ (ជា១០០០តោន) 6

តារាង៥-វារីវប្បកម្មត្រីសមុទ្រ និងទឹកសាបឆ្នាំ ១៩៨៥-២០០៩(ជា១០០០តោន) 8

តារាង៦-វារីវប្បកម្មត្រីសមុទ្រ និងទឹកសាបឆ្នាំ ២០០៥-២០០៩ 8

តារាង៧-ចំនួនត្រីទឹកសាប និងទឹកសមុទ្រដែលបានកែច្នៃឆ្នាំ ២០០៥-២០០៩ (ជាតោន) 9

តារាង៨-ចំនួនត្រីទឹកសាបកែច្នៃឆ្នាំ ១៩៩៥-២០០៩ (ជាតោន) 10

តារាង៩-ចំនួនត្រីសមុទ្រសំខាន់ៗកែច្នៃឆ្នាំ ២០០៦-២០០៩ (ជាតោន) 11

តារាង១០-ចំនួនត្រីនាំចេញឆ្នាំ ២០០៥-២០០៩ (ជាតោន) 12

តារាង១១-សមត្ថភាពសិក្សារបស់បុគ្គលិកបច្ចេកទេស 13

តារាង១២-ករណីបទល្មើសឆ្នាំ ២០០៦-២០០៩ 13

តារាង១៣-ចំនួនកន្លែងភ្ញាស់កូនត្រី និងចំនួនកូនត្រីឆ្នាំ ២០០៦-២០០៩ (ជា១០០០ក្បាល) 18

## I.សេចក្តីផ្តើម

កសិកម្មជាសសរទ្រូងដែលទ្រទ្រង់សេដ្ឋកិច្ចកម្ពុជាជាយូរលង់ណាស់មកហើយ ។ ថ្វីត្បិតតែកសិកម្មនៅតែបានចូលរួមយ៉ាងសំខាន់ក្នុងផលិតផលក្នុងស្រុកសរុប (GDP) ក៏ដោយ ក៏ការរួមចំណែកនេះមានការថយចុះជាលំដាប់ពី ៤៥.៦% នៅឆ្នាំ ១៩៩៣ ដល់២៩.៧%នៅឆ្នាំ ២០០២ ។ តែចាប់ពីឆ្នាំ២០០៨មក ការរួមចំណែកនេះក៏បានចាប់ផ្តើមងើបឡើង វិញ គឺលើសពី ៣០% (តារាងទី១) ។ តួលេខនេះ បានបង្ហាញឱ្យឃើញថា រាជរដ្ឋាភិបាលបាន យកចិត្តទុកដាក់ដោយសង្កត់ធ្ងន់ទៅលើការអភិវឌ្ឍវិស័យកសិកម្មឡើងវិញ ។

តារាង១. អត្រារួមចំណែកជាភាគរយរបស់វិស័យកសិកម្មក្នុងផលិតផលក្នុងស្រុកសរុប (GDP) ឆ្នាំ ១៩៩៩-២០០៩

| វិស័យ | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|---|---|---|---|---|---|---|
| កសិកម្ម | 45.6 | 35.9 | 34.9 | 32.2 | 33.2 | 30.6 | 31.4 | 29.6 | 29.7 | 34.4 | 33.5 |
| ដំណាំ | 18.8 | 16.5 | 15.7 | 14.1 | 16.2 | 15.0 | 16.9 | 15.4 | 15.5 | 18.1 | 17.8 |
| ផលិតកម្មសត្វ | 8.9 | 5.4 | 5.6 | 5.2 | 5.1 | 4.9 | 4.6 | 4.7 | 4.6 | 5.3 | 5.2 |
| នេសាទ | 13.6 | 10.8 | 10.6 | 10.0 | 9.4 | 8.4 | 7.8 | 7.6 | 7.4 | 8.6 | 8.6 |
| ព្រៃឈើ | 4.3 | 3.3 | 3.0 | 2.8 | 2.5 | 2.3 | 2.2 | 2.2 | 2.2 | 2.4 | 2.0 |

ប្រភព MAFF Annual Report 2008-2009

ជលផលកម្ពុជា ជាធនធានសាធារណៈយ៉ាងសំខាន់មួយដែលដើរតួយ៉ាងពិសេសនៅតំបន់ជនបទ តាមរយៈការផ្តល់ជីវជាតិ Protein ជាង៨០%ដល់ប្រជាពលរដ្ឋ ។ លើសពីនេះទៅទៀតជលផលៈ

–បានចូលរួមបង្កើតការងារជូនប្រជាពលរដ្ឋ។ មានប្រជាជនជាង ៦លាននាក់ ដែលទាក់ទងនឹងអាជីវកម្មផ្នែកនេសាទ ។

-បានធ្វើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋនៅតំបន់នេសាទមានជីវភាពល្អប្រសើរឡើង។

-បានបង្កើតឱ្យមានសុវត្ថិភាពចំណីអាហារដោយប្រជាពលរដ្ឋម្នាក់ៗហូបត្រី៥២,៤ គីឡូក្រាមក្នុងមួយឆ្នាំ និង

-បានធ្វើឱ្យសេដ្ឋកិច្ចជាតិមានការរីកចំរើនតាមរយៈការបង់ថ្លៃឈ្នួលដែននេសាទ និងសកម្មភាពទេសចរណ៍។

ផលផលនៅទឹកសាបបានផ្ដល់ប្រាក់ចំណូលពី ៨០០ ទៅ ១ ០៣៥លានដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំ ។ រីឯផលផលសមុទ្របានផ្ដល់ប្រាក់ចំណូលប្រហែលពី៩៧ ទៅ១១៧ លានដុល្លារ។

ក្នុងនាមជាផ្នែកមួយនៃវិស័យកសិកម្ម ជលផលនៅតែបន្តចូលរួមចំណែកយ៉ាងសំខាន់ និងទៀងទាត់រាល់ឆ្នាំ ក្នុងអត្រា រវាង២៥ភាគរយ (តារាងទី២) ។

តារាងទី២. អត្រារួមចំណែកភាគរយនៃអនុវិស័យនីមួយៗរបស់វិស័យកសិកម្ម ២០០៥-២០០៩

| អនុវិស័យ | 2005 | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|---|
| ដំណាំ | 50.9 | 50.8 | 52.2 | 52.7 | 52.9 |
| ផលិតកម្មសត្វ | 15.4 | 15.8 | 15.6 | 15.5 | 15.3 |
| នេសាទ | 26.3 | 25.9 | 24.8 | 25.0 | 25.2 |
| ព្រៃឈើ | 7.4 | 7.5 | 7.3 | 6.9 | 6.6 |

ប្រភព MAFF Annual Report 2000-2010

## II.ស្ថានភាពជលផលពីដើមរហូតមកដល់បច្ចុប្បន្ន

សភាពដែលគួរឱ្យកត់សំគាល់ក្នុងវិស័យជលផល គឺការប្រើប្រាស់ផលិតផលជលផលដែលជាវត្ថុធាតុដើម ដែលបានបង្កើតមកស្ទើរតែទាំងអស់ ថ្វីត្បិតតែគេពុំសូវប្រើប្រាស់ទឹកកក ឬបង្កកក្នុងទឹកកក ក៏ដោយ ។ ត្រី ដែលគេបានចាប់មកត្រូវគេចូលចិត្ត បរិភោគជាត្រីស្រស់ និងកែច្នៃទៅ ជាត្រី ផ្សេងៗសម្រាប់ទុកបរិភោគទៅថ្ងៃក្រោយ និងធ្វើជាចំណីសម្រាប់ផ្ដល់ឱ្យកសិកម្មចញ្ចឹមត្រី ឬចិញ្ចឹមសត្វ ដូចជា មាន់ ឬជ្រូក ។ ផលនេសាទទាំងអស់ត្រូវបានប្រមូលមកពីការចាប់ត្រីនៅ ក្នុងដែននេសាទទឹកសាប និងដែននេសាទសមុទ្រ និងវារីវប្បកម្ម (តារាងទី៣) ។

### ១-ជលផលទឹកសាប

ផ្ទៃដីរបស់កម្ពុជាប្រមាណ៨៥ភាគរយស្ថិតនៅក្នុងអាងទន្លេមេគង្គ ។ ពីសង្គមមុនព្រៃលិចទឹកមាន ប្រហែល១លានហិចតា ឬ ៥.៥ ភាគរយនៃផ្ទៃដីរបស់កម្ពុជា ។ ក្នុងអំឡុងពេលពីឆ្នាំ ២០០១ ដល់ ២០០៨ ផលិតផលត្រីទឹកសាបដែលគេចាប់បានប្រហែលពី ៣១៩.០០០

តារាងទី៣ . ផលផលទឹកសាប សមុទ្រ និងវារីវប្បកម្ម ២០០៥-២០០៩ (ជា១០០០តោន)

| ផ្នែក | 2005 | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|---|
| ទឹកសាប | 324.0 | 422.0 | 395.0 | 365.0 | 390.0 |
| សមុទ្រ | 60.0 | 60.5 | 63.5 | 66.0 | 75.0 |
| វារីវប្បកម្ម | 26.0 | 34.2 | 35.3 | 40.0 | 50.0 |
| សរុប | 410.0 | 516.7 | 493.8 | 471.0 | 515.0 |

ប្រភព MAFF Annual Report 2009-2010

តោន ដល់៤៥០.០០០តោន ក្នុងមួយឆ្នាំ ឬ ៨១ ភាគរយនៃត្រីដែលគេចាប់បានទាំងអស់ក្នុងស្រុក ចែកជា ៖

–នេសាទលក្ខណៈឧស្សាហកម្ម :

-ឡូត៍នេសាទ ២៥,០០០តោន-៧៥,០០០តោន

-ដាយ ១៨,០០០តោន-៣០,០០០តោន

– នេសាទលក្ខណៈសិប្បកម្ម ៨៥,០០០តោន-១០០,០០០តោន

– នេសាទលក្ខណៈគ្រួសារ ១១៥,០០០តោន-១២០,០០តោន

– នេសាទតាមវាលស្រែ ៧៥,០០០តោន-១២៥,០០០តោន

នៅឆ្នាំ២០០៦ ព្រះរាជាណាចក្រកម្ពុជាបានទទួលចំណាត់ថ្នាក់លេខ៥លើពិភពលោកជាប្រទេសផ្គត់ផ្គង់ត្រីទឹកសាបបន្ទាប់ពីប្រទេសចិន បង់ក្លាដេស ឥណ្ឌា និងមីយ៉ាន់ម៉ា។

សម្រាប់ នេសាទលក្ខណៈឧស្សាហកម្ម ដូចជា ណរត់ឈ្លូង ឬណារ៉ាវ (Arrow Shaped Trap),ផ្ទស់ (Barrage Fishing), ឡូត៍ដាយ(Dai Fishing) ត្រូវបានគេប្រើប្រាស់នៅក្នុងទន្លេសាប។ នៅមានឧបករណ៍នេសាទ ជាច្រើនទៀតប្រហែល ១៥០ ប្រភេទដែលគេប្រើប្រាស់សម្រាប់ចាប់ត្រីក្នុងប្រទេសទាំងមូល ។

បឹងទន្លេសាបជាប្រភពទឹកសាបធម្មជាតិមួយយ៉ាងធំជាងគេនៅតំបន់អាស៊ីអាគ្នេយ៍។ ទន្លេសាបស្ថិតនៅភូមិភាគខាងជើងឈៀងខាងលិចនៃប្រទេសកម្ពុជា ហើយមានទំហំនៅរដូវប្រាំងពី ២៥០០-៣០០០គីឡូម៉ែត្រការ៉េ ទៅ ១០,០០០-១៦,០០០គីឡូម៉ែត្រការ៉េនៅរដូវវស្សា។



ភាគច្រើនមិនត្រឹមតែដកដង្ហើមស្រូបយកអុកស៊ីសែនរលាយក្នុងទឹក ថែមទាំងអាចដកដង្ហើមស្រូបយកអុកស៊ីសែនពីបរិយាកាស ហើយជាប្រភេទត្រីធន់អាចរស់នៅលើគោកបានយូរ និងអាចវារលើដីគោកដើម្បីស្វែងរកមជ្ឈដ្ឋានទឹកថ្មី។

ការធ្វើអាជីវកម្មនេសាទទឹកសាបត្រូវបានចែកជាបីលក្ខណៈ ៖ ការនេសាទជាលក្ខណៈគ្រួសារ សិប្បកម្ម និងឧស្សាហកម្ម។ លក្ខណៈនេសាទនីមួយៗត្រូវគោរពច្បាប់ជាធរមានដែលបានចែងអំពីការដាក់កម្រិតផ្សេងៗ ពាក់ព័ន្ធទៅនឹងឧបករណ៍ចាប់ត្រី ទីកន្លែង ទំហំ និងចំនួនឧបករណ៍នៅ រដូវបើកបិទ នេសាទ ។ល។

ការនេសាទជាលក្ខណៈគ្រួសាររួមទាំងការនេសាទតាមវាលស្រែពុំសូវមានច្បាប់ទម្លាប់តានតឹងទេ គេអាចនេសាទបានគ្រប់ពេលវេលា។

ការនេសាទជាលក្ខណៈសិប្បកម្មប្រព្រឹត្តទៅនៅក្រៅឡូត៍នេសាទ នៅកណ្តាលទន្លេសាប និងតាមព្រែក ទន្លេទាំងឡាយ ហើយមានច្បាប់គ្រប់គ្រង តែការត្រួតពិនិត្យមានការលំបាកជាខ្លាំង ដោយសារឧបករណ៍ប្រើប្រាស់ជាលក្ខណៈគ្រួសារមានចំនួន ឬប្រវែងប្រហាក់ប្រហែលនឹងឧបករណ៍លក្ខណៈសិប្បកម្ម ។ ត្រីដែលគេនេសាទបានក្នុងលក្ខណៈគ្រួសារត្រូវបានគេលក់ដូរនៅផ្ទាល់នឹងទីកន្លែងពុំបាច់យកមកទីផ្សារនៅភ្នំពេញឡើយ ។

ការនេសាទជាលក្ខណៈឧស្សាហកម្មប្រព្រឹត្តទៅនៅក្នុងឡូត៍នេសាទដែលគេបានដេញថ្លៃពីរឆ្នាំម្តង ។ ឡូត៍ទាំងនោះត្រូវបានគេរៀបចំឡើងតាមមាត់ទន្លេ និងដៃទន្លេសាប តាមទន្លេមេគង្គ ទន្លេបាសាក់ រហូតដល់ទល់ដែនប្រទេសវៀតណាម ។ នៅក្នុងបឹងទន្លេសាប ឡូត៍នេសាទនីមួយៗអាចមានបណ្តោយពី ១៥-២៥គីឡូ ម៉ែត្រ និងទទឹងពី៥ទៅ ១០គីឡូម៉ែត្រ ។

គេចែកលំដាប់ថ្នាក់ត្រីទៅតាមទំហំ និងប្រភេទរបស់ត្រី ។ ត្រីលេខ១ គឺប្រភេទត្រីដែលមានទម្ងន់ពី១គីឡូក្រាមឡើងទៅ ។ មានត្រីចំនួន១៩ប្រភេទ ដែលចូលក្នុងចំណាត់ថ្នាក់នេះ ។ ត្រីលេខ២ គឺត្រីទម្ងន់ពី ០.៥ទៅ ១.០គីឡូក្រាម ។ ត្រីលេខ៣មានទម្ងន់ពី ០.៥០គីឡូក្រាមចុះក្រោម ។ តែមានត្រីតូចៗខ្លះក៏អាចចាត់ចូលជាលេខ១បានដែរ ដោយមានគុណភាពពិសេស ។

២-ជលផលសមុទ្រ

ព្រះរាជាណាចក្រកម្ពុជាមានឆ្នេរសមុទ្រប្រវែង ៤៣៥គីឡូម៉ែត្រ លាតសន្ធឹង នៅក្នុងខេត្តកំពត, កែប, ព្រះសីហនុ និងកោះកុង ។ លើផ្ទៃសមុទ្រមានកោះជាច្រើន។ ដែនដីសមុទ្រដែលជាតំបន់សេដ្ឋកិច្ចផ្តាច់មុខ (Exclusive Economic Zone, EEZ)គ្រប់ដណ្តប់លើផ្ទៃសមុទ្រចំនួន៥៥ ០០០ គីឡូម៉ែត្រការ៉េ ដែលមានទឹករាក់ជំរៅប្រហែលតែ៥០ម៉ែត្រជាមធ្យម។ តាមការប៉ាន់ស្មានពីអាជ្ញាធរថាមានកាណូតចំនួនប្រហែល៥ ០០០ គ្រឿង ដែលធ្វើសកម្មភាពនេសាទត្រីក្នុងតំបន់នេះ។ អង្គការFAO បានទទួលស្គាល់ថា ឈូងសមុទ្រសៀម ជាតំបន់មួយដែលបានផ្តល់ផលត្រីច្រើនជាងគេក្នុងពិភពលោក ហើយផ្ទៃសមុទ្រខ្មែរនៅតំបន់ដែលផ្តល់

ផលផលច្រើនជាងគេក្នុងចំណោមខេត្តទាំងបួន(តារាងទី៤) ។

តារាងទី៤. ចំនួនត្រីសមុទ្រដែលចាប់បានតាមខេត្ត២០០៥-២០០៩ (គិតជា១០០០តោន)

| ខេត្ត | 2005 | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|---|
| សរុបរួម | 60.0 | 60.5 | 63.5 | 66.0 | 75.0 |
| ខេត្តព្រះសីហានុ | N/A | 23.4 | 22.0 | 27.0 | 32.0 |
| កំពត | N/A | 7.4 | 5.6 | 6.4 | 5.6 |
| កោះកុង | N/A | 29.3 | 35.6 | 32.6 | 37.4 |
| កែប | N/A | 0.4 | 0.3 | N/A | N/A |

ប្រភព: Fisheries Administration Annual Report 2009

Statistical Yearbook 2008

តាមសេចក្តីរាយការណ៍របស់រាជរដ្ឋាភិបាល កាណូតសៀមដែលមានច្បាប់ បានចាប់ត្រីក្នុងដែនសមុទ្រកម្ពុជាពី២៦ ៥០០ ទៅ៣៧ ៥០០ តោនក្នុង១ឆ្នាំៗ ចាប់ពីឆ្នាំ២០០២មកម្ល៉េះ។ លើសពីនេះទៀត មានការចាប់ត្រីខុសច្បាប់ផងដែរពីសំណាក់កាណូតដែលចូលមកពីប្រទេសសៀម និងប្រទេសវៀតណាម។

បើប្រៀបធៀបទៅនឹងការនេសាទទឹកសាប ចំនួនត្រីសមុទ្រហាក់ដូចជាមិនសំខាន់ប៉ុន្មានឡើយ ប៉ុន្តែការនេសាទត្រីសមុទ្របានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋតាមសមុទ្រមានជីវភាពប្រសើរដូចជាប្រាក់ចំណូល និងការងារ ។ ជាពិសេសទៅទៀតផលផលសមុទ្រភាគច្រើនត្រូវបាននាំចេញទៅប្រទេសក្រៅ ។

៣-វារីវប្បកម្ម

វារីវប្បកម្មក្នុងពិភពលោកបានរីកចម្រើនយ៉ាងច្រើនក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ហើយក៏បានផ្តល់១/៣នៃផលផលសរុបក្នុងពិភពលោក បើប្រៀបធៀបទៅនឹងឆ្នាំ១៩៧០ដែលបានផ្តល់តែ៤ភាគរយប៉ុណ្ណោះ។ បូករួមទាំងរុក្ខជលផលសមុទ្រផង វារីវប្បកម្មបានផ្តល់ផលផលដល់ទៅ៦៦,៧លានតោន ហើយមានតម្លៃជាសាច់ប្រាក់សរុបដល់ទៅ ៨៥,៩ពាន់លានដុល្លារអាមេរិក។

នៅក្នុងឆ្នាំ២០០៦ វារីវប្បកម្មនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិកបានផ្តល់ផលផល គិតជាបរិមាណមានចំនួន៨៩ភាគរយ និងជាសាច់ប្រាក់មានចំនួន៧៧ភាគរយ។ ប្រទេសចិន

ប្រជាមានិត ជាប្រទេសលេខ១ ដែលបានផ្តល់ផលផលិតជាបរិមាណមានចំនួន៦៧ភាគរយ និងជាសាច់ប្រាក់មានចំនួន៨៩ភាគរយ។

ដោយសារជលផលត្រីធម្មជាតិមានគ្រប់គ្រាន់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ការធ្វើវារីវប្បកម្មពុំសូវជុះដាលឡើយ ។ ម្យ៉ាងទៀតដោយសារលក្ខណៈពិសេសរបស់ទន្លេមេគង្គ និងទន្លេសាប, ការនេសាទត្រីមានលក្ខណៈផ្លាស់ប្តូរទៅតាមរដូវ ។ អ្នកនេសាទនៅក្នុងទន្លេសាប និងដងទន្លេសាប បានប្រោះកូនត្រីដែលសល់ពីការទទួលទាននៅក្នុងបែរ ឬស៊ីងដើម្បីចិញ្ចឹម។ ហើយបន្តលែងកូនត្រីដើម្បីចិញ្ចឹមក្នុងបៃ ឬស៊ីងរបស់គាត់សម្រាប់ទុកលក់នៅរដូវបិទនេសាទ។ នៅតាមឆ្នេរសមុទ្រការអនុវត្តវារីវប្បកម្មក៏ពុំសូវរីកចម្រើនដោយសារត្រីសមុទ្រពុំមែនជាត្រី ដែលប្រជាពលរដ្ឋខ្មែរចូលចិត្តធ្វើជាស្បៀងអាហារប្រចាំថ្ងៃទេ ហើយច្រើនតែនាំចេញទៅលក់នៅបរទេស ។

នៅអំឡុងពេលមុនឆ្នាំ១៩៥០ ពុំមានឯកសារណាបញ្ជាក់ថា មានអនុវត្តន៍វារីវប្បកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងឡើយ ។ ប៉ុន្តែនៅចន្លោះឆ្នាំ១៩៦៤-១៩៦៩ វារីវប្បកម្មបានផ្តល់ផលពី ៤០០០-៦០០០តោនក្នុងមួយឆ្នាំ ហើយនៅឆ្នាំ ១៩៧០ បានផ្តល់ ៣០០០តោន ។ ការអនុវត្តវារីវប្បកម្មត្រូវបានបញ្ឈប់នៅចន្លោះឆ្នាំ ១៩៧៥-១៩៧៩ រហូតដល់ ១៩៧៩-១៩៨០ ទើបចាប់ផ្តើមឡើងវិញទៀត ។

វារីវប្បកម្មនៅប្រទេសកម្ពុជា គឺធ្វើតាមការចិញ្ចឹមត្រីក្នុងបែរដែលមានចំនួនប្រហែល ៤៥០០ (ឆ្នាំ២០០៨)៖ តាមដងទន្លេមេគង្គមាន៣៣ភាគរយ តាមដងទន្លេសាប១៧ភាគរយ និងក្នុងទន្លេសាប៤៣ភាគរយ ហើយបានផ្តល់ពី៧០ ទៅ៨០ភាគរយនៃផលវារីវប្បកម្មទាំងមូល។ រីឯបរិមាណសេសសល់បានមកពីការចិញ្ចឹមត្រីក្នុងស្រះ។ ចំនួនស្រះចិញ្ចឹមត្រីបានកើនឡើងជាលំដាប់ ពី៣ ៤៥៥ស្រះក្នុងឆ្នាំ១៩៩៧ ដល់៥៦ ២៣៤ស្រះក្នុងឆ្នាំ២០០៩។ ផលត្រីដែលបានមកពីការចិញ្ចឹមត្រីក្នុងស្រះពុំសូវបានច្រើនឡើយ ដោយខ្វះបច្ចេកទេស និងការថែទាំត្រីឲ្យបានដិតដល់។

រដ្ឋបាលជលផលចាប់ផ្តើមកត់ត្រាស្ថិតិជាផ្លូវការអំពីវារីវប្បកម្មចាប់តាំងពីឆ្នាំ ១៩៨៤មក (តារាងទី៥) ។ តួលេខបានបង្ហាញឱ្យឃើញថា វារីវប្បកម្មមានការប្រែប្រួលឡើងចុះ តែគិតជារួមមានការកើនឡើងជាលំដាប់។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ កំណើនវារីវប្បកម្មប្រចាំឆ្នាំរបស់យើងមាន ប្រហែល១៥ភាគរយប៉ុណ្ណោះ គឺមានកម្រិតទាបនៅឡើយ បើប្រៀបធៀបទៅ

នឹងប្រទេសជិតខាងដូចជាប្រទេសក្នុងភូមិភាគអាស៊ី ប៉ាស៊ីហ្វិក មាន៦២%, ប្រទេសថៃ៤២% ប្រទេសម៉ាឡេស៊ី៤៨% ប្រទេសវៀតណាម៥១% និងប្រទេសឡាវ ១៣% ។

តារាងទី៥ ៖ វារីវប្បកម្មត្រីសមុទ្រ និងទឹកសាបឆ្នាំ ១៩៨៥-២០០៤ (១០០០តោន)

| ផ្នែក | 1985 | 1990 | 1995 | 2000 | 2001 | 2002 | 2003 | 2004 |
|---|---|---|---|---|---|---|---|---|
| បូកសរុប | 3.0 | 6.4 | 8.8 | 14.4 | 17.5 | 18.2 | 26.3 | 20.8 |
| ត្រីសមុទ្រ | 0.1 | 0.1 | 0.1 | 0.6 | 3.6 | 3.9 | 8.2 | 0.1 |
| ត្រីទឹកសាប | 2.9 | 6.3 | 8.7 | 13.8 | 13.9 | 14.3 | 18.1 | 20.7 |

ប្រភព: Statistical Yearbook 2008

ត្រីចិញ្ចឹមមានតួនាទីសំខាន់ក្នុងការផ្គត់ផ្គង់ត្រីទឹកសាបដល់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងទីក្រុងដូចជានៅឆ្នាំ ១៩៩២ ត្រីចិញ្ចឹមចំនួន ៦៥% ត្រូវបានចិញ្ចឹម នៅតែក្នុងខេត្ត៤ គឺខេត្តកណ្តាល ២១.៥% បាត់ដំបង ១៥.៤% ភ្នំពេញ ១៤.១% និងសៀមរាប ១៣.៥% ។ ក្នុងឆ្នាំ ២០០៧ខេត្តកណ្តាល និងទីក្រុងភ្នំពេញបានផ្តល់ផលត្រីចិញ្ចឹមចំនួន៤៩ភាគរយនៃផលវារីវប្បកម្មទាំងមូល និងកូនត្រីសម្រាប់ចិញ្ចឹមចំនួន៥៧ភាគរយ។ នៅពេល ថ្មីៗនេះ ដោយសារចំនួនប្រជាពលរដ្ឋចេះតែកើនឡើង ចំនួនត្រីធម្មជាតិចេះតែថយចុះ (ទឹក សាប និងទឹកប្រៃ) និងដោយសារការចិញ្ចឹមត្រីនៅប្រទេសជិតខាងបានទទួលជោគជ័យក្នុងការបង្កើនប្រាក់ចំណូល ធ្វើឲ្យការអនុវត្តវារីវប្បកម្ម បានបោះជំហានយ៉ាងរហ័សក្នុងទូទាំងប្រទេស (តារាងទី៦)។

តារាងទី៦. វារីវប្បកម្មត្រីសមុទ្រ និងទឹកសាប ឆ្នាំ ២០០៥-២០០៩

| ប្រភេទ | ឯកតា | 2005 | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|---|---|
| ត្រី និងបង្គារ | 1000 Tons | 26.0 | 34.2 | 35.3 | 40.0 | 50.0 |
| សារាយសមុទ្រ | Tons | 18,000 | 6,810 | N/A | N/A | N/A |
| ក្រពើ | Heads | 120,000 | 137,642 | 128,945 | 156,500 | 185,000 |
| ភ្ញាស់កូនត្រី | 1000 heads | 18,733 | 21,335 | 33,778 | 37,193 | 69,750 |

ប្រភព: Fisheries Administration Annual Report 2005-2009

វារីវប្បកម្មមួយទៀតដែលគួរយកចិត្តទុកដាក់ គឺការចិញ្ចឹមក្រពើ (តារាងទី៦) ។ ផ្អែកលើការពិសោធន៍របស់ប្រទេសថៃ ការយកកូនក្រពើដែលមានប្រវែងប្រហែល ៣០សង្ទីម៉ែត្រ មកចិញ្ចឹមបានផ្តល់ការទុកចិត្តឱ្យកូនក្រពើនោះអាចរស់ធំធាត់បានដោយជោគជ័យ ។ ចាប់តាំង

ពីឆ្នាំ ២០០៥មក ការចិញ្ចឹមក្រពើបានរីកឡើងជាលំដាប់ ដោយសារតម្រូវការរបស់ទីផ្សារអន្តរជាតិមានកម្រិតកាន់តែខ្ពស់ ។

នាពេលអនាគតត្រីចិញ្ចឹមដែលបានមកពីការធ្វើវារីវប្បកម្មនឹងក្លាយទៅជាប្រភពយ៉ាងសំខាន់សម្រាប់ផ្គត់ផ្គង់សេចក្តីត្រូវការនៅតាមទីផ្សារ ។ តាមការប៉ាន់ស្មានរបស់អ្នកចិញ្ចឹមត្រី គេបានឱ្យដឹងថា ដើម្បីបានផលត្រីចិញ្ចឹមមួយគីឡូក្រាម គេត្រូវការត្រីល្អិតចំនួន៤ ទៅ៥គីឡូក្រាមជាចំណីសម្រាប់ប្រភេទស៊ីសាច់ជាអាហារ ។ ការរីកដាលនៃចំនួន និងទំហំទីក្រុងក៏បានផ្តល់កាកសំណល់ម្ហូបអាហារសេសសល់ជាចំណីត្រីផងដែរ ។ ដូចជាក្នុងប្រទេសជិតខាងដែរ កន្ទក់ជាចំណែកសំខាន់មួយសម្រាប់ធ្វើចំណីត្រី ។ ឯចុងអង្ករក៏ជាចំណែកមួយទៀតដែរ ក្រៅពីនេះនៅមានម្សៅដំឡូងមី ពោត សណ្តែក ក៏ជាសមាសធាតុសំខាន់សម្រាប់ជាចំណីត្រីផងដែរ។ ការចិញ្ចឹមត្រីនៅបច្ចុប្បន្នត្រូវការកន្ទក់ប្រហែល១០%នៃកន្ទក់ ដែលមានក្នុងស្រុកតែប៉ុណ្ណោះ។ តម្រូវការនេះប្រហែលជាមិនអាចកើនឡើងបានឡើយ ដោយសារមានការប្រជែងពីការចិញ្ចឹមគោ និងជ្រូកដែលត្រូវការកន្ទក់នេះដែរ ។

៩.ផលផលកែច្នៃ

ថ្វីត្បិតតែប្រជាពលរដ្ឋខ្មែរយើងចូលចិត្តបរិភោគត្រីស្រស់ៗក៏ដោយ ចំនួនត្រីទឹកសាបជាច្រើន និងត្រីសមុទ្របន្តិចបន្តួច ក៏បានត្រូវគេកែច្នៃសម្រាប់បរិភោគនៅពេលក្រោយ និងកែច្នៃជាចំណីសម្រាប់សត្វ ។ ផលផលកែច្នៃភាគច្រើនត្រូវបានប្រើប្រាស់ជាអាហារក្នុងស្រុក ។ ចំពោះផលផលកែច្នៃដែលមានគុណភាពល្អត្រូវបាននាំចេញទៅប្រទេសជិតខាង ។ បច្ចេកទេសកែច្នៃមានដូចជា ហាលថ្ងៃ ប្រឡាក់អំបិលហាលថ្ងៃ, ឆ្អើរ និងចំហុយ។ ជាបន្ថែមទៀតមានធ្វើជាប្រហុក និងទឹកត្រីដែលប្រើត្រីល្អិតៗ និងត្រីសមុទ្រដែលមានថ្លៃទីផ្សារទាប ។ ក្នុងការនេសាទសមុទ្រចំនួនត្រីដែលមានថ្លៃទីផ្សារទាបអាចមានកម្រិតដល់ទៅ៧០% ។

តារាងទី៧. ផលិតផលផលផលទឹកសាប និងសមុទ្រកែ ច្នៃពី ២០០៥-២០០៩ (ជាតោន)

| ប្រភេទកែច្នៃ | 2005 | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|---|
| ទឹកសាប | 23,500 | 50,000 | 41,500 | 38,000 | 39,00 |
| សមុទ្រ | 4,500 | 4,300 | 4,850 | 5,300 | 5,500 |
| សរុប | 28,000 | 54,300 | 46,350 | 43,300 | 44,500 |
| ទឹកត្រី(១០០០លីត្រ) | 11,260 | 18,553 | 15,000 | 25,500 | 28,000 |

ប្រភព Fisheries Administration Annual Report 2005-2009

តារាងទី៨ បង្ហាញពីផលផលកែច្នៃសំខាន់ៗដែលផ្សំពីត្រីទឹកសាប ។ ប្រភេទកែច្នៃនេះជាប្រភពអាហារ ចាំបាច់សម្រាប់ប្រជាពលរដ្ឋខ្មែរ ជាពិសេសនៅទីជនបទ ។

តារាងទី៨. ផលិតផលផលផលទឹកសាបកែច្នៃពី១៩៩៥-២០០៩ (ជាតោន)

| ប្រភេទកែច្នៃ | 1995 | 2000 | 2003 | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|---|---|---|
| ត្រីងៀត | 1,115 | 1,854 | 2,462 | 4,026 | 4,700 | 4,435 | 4,387 |
| ត្រីឆ្អើរ | 453 | 512 | 1500 | 824 | 1,187 | 1,315 | 672 |
| ត្រីប្រឡាក់ | 5,353 | 2,544 | 1,040 | 3,100 | 4,135 | 4,570 | 3,720 |
| ផ្អក | 1,252 | 1,165 | 1,726 | 6,120 | 3,020 | 2,225 | 1,317 |
| ប្រហុក | 2,033 | 7,187 | 14,474 | 34,920 | 27,400 | 24,600 | 28,130 |
| ម៉ាំ | 1,147 | 2,447 | 866 | 590 | 467 | 375 | 305 |
| សរុប | 11,353 | 15,709 | 22,068 | 49,580 | 40,909 | 37,520 | 38,531 |
| ទឹកត្រី(១០០០ លីត្រ) | 1,866 | 5,420 | 10,952 | 16,642 | 13,000 | 20,500 | 26,135 |

ប្រភព: Fisheries Administration Annual Report 2005-2009

Statistical Year Book 2008

តារាងទី៩ បង្ហាញតួលេខត្រីសមុទ្រកែច្នៃពីឆ្នាំ ២០០៦-២០០៩ ។ បើប្រៀបធៀបទៅនឹងត្រីទឹកសាប, តារាងតួលេខនេះបានបង្ហាញប្រាប់ថា ចំនួនត្រីសមុទ្រកែច្នៃពុំសូវសំខាន់ឡើយ ប៉ុន្តែតម្លៃនាំចេញមានសារៈសំខាន់ណាស់ ។

៥-ការនាំត្រីចេញទៅបរទេស

ត្រីផ្តល់ជាតិប្រូតេអ៊ីនចំនួន ជាង៨០% ដល់ប្រជាពលរដ្ឋខ្មែរ ។ ប្រជាពលរដ្ឋខ្មែរម្នាក់ៗបរិភោគសាច់ត្រីចំនួន ៥២,៤ គីឡូក្រាមក្នុងមួយឆ្នាំ ។ នៅតំបន់បឹងទន្លេសាបប្រជាពលរដ្ឋម្នាក់ៗបរិភោគសាច់ត្រីរហូតទៅដល់ ៦៧-៨០ គីឡូក្រាមក្នុងមួយឆ្នាំ ។ ជាមធ្យមប្រជាពលរដ្ឋក្នុងពិភពលោកម្នាក់ៗបរិភោគសាច់ត្រីពី ១៥-៩០គីឡូក្រាមក្នុងមួយឆ្នាំ ។ ដូច្នេះចំនួនបរិភោគមធ្យមរបស់ពលរដ្ឋខ្មែរដែលមានកម្រិតជាង៥០គីឡូក្រាមស្ថិតនៅប្រហែលលើសពាក់កណ្តាលមធ្យមរបស់សកលលោក ។

តារាងទី៩. ផលិតផលជលផលសមុទ្រកែច្នៃសំខាន់ខ្លះៗពីឆ្នាំ ២០០៦-២០០៩ (ជាតោន)

| ប្រភេទកែច្នៃ | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|
| ត្រីងៀត | 157 | 193 | 190 | 135 |
| ត្រីចំហុយ | 619 | 655 | 755 | 555 |
| មឹកក្រៀម | 238 | 251 | 290 | 286 |
| បង្គារក្រៀម | 37 | 85 | 85 | 100 |
| សាច់បង្គារបក | 368 | 265 | 430 | 485 |
| បង្គារបង្កក | N/A | 234 | 200 | 200 |
| សាច់ក្តាម | 285 | 384 | 510 | 634 |
| ក្តាមស្ងោរ | 430 | 269 | 250 | 300 |
| សម្បកក្តាមស្ងួត | 27 | 81 | 115 | 294 |
| ម្សៅត្រី | 790 | 660 | 680 | 625 |
| កាពិ | 70 | 40 | 650 | 749 |
| សរុប | 3,021 | 3,117 | 4,155 | 4,363 |

ប្រភព Fisheries Administration Annual Report 2006-2009

បរិមាណត្រីដែលលើសពីការបរិភោគក្នុងស្រុកត្រូវបាននាំចេញទៅបរទេស ។ ព្រះរាជាណាចក្រកម្ពុជាមានទម្លាប់ នាំចេញត្រីទឹកសាបទៅប្រទេសថៃតាំងពីឆ្នាំ១៩៣០មកម្ល៉េះ ព្រមទាំងមួយចំនួនខ្លះទៀតនាំចេញទៅប្រទេសវៀតណាម។ ប្រទេសទាំងពីរជាទីផ្សារចម្បងរបស់កម្ពុជា។ ប្រទេសខ្លះទៀតដែលនាំចូលត្រីពីកម្ពុជាដែរមានប្រទេសអូស្ត្រាលី ចិនប្រជាមានិត សិង្ហបុរី ហុងកុង បារាំង និងសហរដ្ឋអាមេរិក ។ ប្រភេទត្រីដែលនាំចេញមានក្រុមត្រីឥតស្រកាត្រី មានស្រកា មឹក បង្គារ ក្តាម និងសម្បកខ្យង សម្រាប់ធ្វើឡេវអារ និងបិទក្នុងឈើធ្វើទូ តុ ។

ប្រភេទត្រីសមុទ្រត្រូវបាននាំចេញតាមយន្តហោះពីភ្នំពេញ ឬតាមសមុទ្រពីខេត្តព្រះសីហនុ ។ ការនាំចេញតាមសមុទ្រ រួមមានផលិតផលស្រស់ ឬនៅរស់។ ត្រីទឹកសាបមួយចំនួនត្រូវឈ្មួញដាក់ទឹកកក ហើយដឹកតាមឡានទៅលក់នៅប្រទេសថៃ រួមមានអន្ទង់ និងកង្កែបផងដែរ ។ ត្រីកែច្នៃដែលមានគុណភាពល្អ ក៏ឈ្មួញបាននាំចេញទៅប្រទេសថៃផងដែរ ។ ត្រីទឹកសាបដែលឈ្មួញបានប្រឡាក់អំបិលហើយ សម្រាប់យកទៅកែច្នៃបន្ត ឬក៏ យកទៅធ្វើ

ជាចំណីសត្វត្រូវបានឈ្មួញដឹកតាមកប៉ាល់យកទៅផ្គត់ផ្គង់ទីផ្សារវៀតណាម ឬតាមឡានទៅទីផ្សារថៃ។

រដ្ឋបាលជលផលបានប៉ាន់ស្មានថា ពី៦៥ ទៅ៧០%នៃត្រីសមុទ្រត្រូវបាននាំចេញទៅបរទេសជាពិសេស ប្រទេសថៃ ។ តាមការវាយតម្លៃក្នុងមួយឆ្នាំៗ ការនាំចេញត្រី(ទឹកសាប និងសមុទ្រ) ទៅបរទេសបានបង្កើនប្រាក់ចំណូលប្រហែលជាង ២៥០លានដុល្លារអាមេរិក ។

តារាងទី១០. ចំនួនត្រីនាំចេញ ២០០៥-២០០៩ (ជាតោន)

| ប្រភេទ | 2005 | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|---|
| ត្រីស្រស់ | 42,000 | 19,500 | 16,770 | 17,000 | 20,000 |
| ត្រីកែច្នៃ | 10,000 | 10,500 | 7,330 | 8,000 | 10,000 |
| សរុប | 52,000 | 30,000 | 24,100 | 25,000 | 30,000 |

ប្រភព: Fisheries Administration Annual Report 2009

Statistical Year Book 2008

ចំនួនត្រីដែលអាចផ្គត់ផ្គង់ទីផ្សារអន្តរជាតិនៅមានកម្រិត តែសេចក្ដីត្រូវការលើធនធានជលផលចេះតែកើនឡើងជានិច្ច ។ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាប្រទេសកម្ពុជាយើង គេពុំសូវទាមទារពន្ធនាំចូលខ្ពស់ឡើយ ។ តែផ្ទុយទៅវិញការលំបាកក្នុងការនាំចេញធនធានជលផល គឺការទាមទារឱ្យមានសំបុត្រស្នាមជាក់លាក់ បញ្ជាក់ពីគុណភាព និងសុវត្ថិភាពម្ហូបអាហារដូចជា SPS ។ សហគមន៍អឺរ៉ុប មិនអនុញ្ញាតឱ្យនាំចូលនូវធនធានជលផលពីប្រទេសកម្ពុជាយើងទេនៅពេលនេះ។ ជាបន្ថែមទៅទៀតអង្គការបរិស្ថានជាច្រើនបានធ្វើការគៀបសង្កត់ឱ្យមានវិធានការតឹងរឹង ដើម្បីការពារត្រីទឹកសាប និងត្រីសមុទ្រ។

៦-សកម្មភាពរបស់រដ្ឋបាលជលផល

ក.បុគ្គលិក

ដើម្បីដំណើរការរបស់ខ្លួន រដ្ឋបាលជលផលមានមន្ត្រីក្របខ័ណ្ឌសរុបចំនួន ១,១២០នាក់ ប្រុស ៩៥៨ និងស្រី ១៦២នាក់ ។ ក្នុងចំណោមមន្ត្រីរាជការទាំងអស់នោះមាន៨៥២នាក់ ត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចនៅតាមខេត្ត។ មានមន្ត្រីចំនួន ៤៧%មានសញ្ញាបត្រពីសាកលវិទ្យាល័យ និង១៧% បរិញ្ញាបត្ររង (តារាង១១) ។

បុគ្គលិកទាំងអស់នេះតែងតែទទួលការអប់រំ (ពេលវែង ឬពេលខ្លី) បន្តជារឿយៗនៅក្នុងស្រុក និងទៅបរទេស ។

តារាង១១. សមត្ថភាពសិក្សារបស់បុគ្គលិកបច្ចេកទេស

| សញ្ញាប័ត្រ | PhD* | MSC* | BSC* | BSC** | AA* | AA** |
|---|---|---|---|---|---|---|
| ចំនួន | 9 | 144 | 307 | 71 | 152 | 42 |

ប្រភព Fisheries Administration Annual Report 2009

*Degree in Fisheries
** Degree in other fields

ខ.សកម្មភាពផ្លូវច្បាប់ និងការបង្ក្រាបបទល្មើស

រដ្ឋបាលជលផលបានខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការបង្កើតច្បាប់ចាំបាច់ សើរើច្បាប់ចាស់ និងបានធ្វើឱ្យព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសទាំងឡាយកាន់តែមានប្រសិទ្ធភាពដើម្បីគ្រប់គ្រងធនធានជលផលឱ្យរឹតតែប្រសើរឡើង ។ ជាពិសេសបានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ដើម្បីបង្ក្រាបបទល្មើសក្នុងទឹកសាប និងដែនសមុទ្រ (តារាង១២) ។ ឧទាហរណ៍ក្នុងឆ្នាំ ២០០៩ បានចាប់បទល្មើសចំនួន ៤,៦៣៣ ករណី ។ ក្នុងនោះ ២,៩២១ ក្នុងទឹកសាប និង១,៧១២ នៅក្នុងសមុទ្រ ។ ជាលទ្ធផលគឺបានផ្តន្ទាទោសដាក់ពន្ធនាគារជនល្មើសចំនួន ១០៧នាក់ ពិន័យចំនួន១៣៣នាក់ និងកំទេចឧបករណ៍បាន ៤,៣៥១ករណី ។

នៅក្នុងឆ្នាំ២០១១ថ្មីៗកន្លងទៅនេះរាជរដ្ឋាភិបាល បានដកឡូត៍នេសាទចំនួន៣៥ឡូត៍ ដោយមូលហេតុ ម្ចាស់ឡូត៍ទាំងនោះបានប្រព្រឹត្តបទល្មើសនេសាទ ដូចជាដាក់សម្រះ ឈ្នះ និងស្បៃមុង។ វិធានការដកឡូត៍នេសាទនេះ ត្រូវបានទទួលការគាំទ្រពីប្រជាជនគ្រប់មជ្ឈដ្ឋាន ព្រោះអាចជាការព្រមានដល់ម្ចាស់ឡូត៍នេសាទដទៃទៀត និងបង្កើនធនធានជលផលកាន់តែច្រើនឡើងនាឆ្នាំបន្តបន្ទាប់។

តារាងទី១២. ករណីបទល្មើស ២០០៦-២០០៩

| ប្រភេទបទល្មើស | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|
| ទឹកសាប | 2,655 | 1,911 | 1,643 | 2,921 |
| សមុទ្រ | 716 | 1,305 | 305 | 1,712 |
| សរុប | 3,371 | 3,216 | 1,948 | 4,633 |

ប្រភព Fisheries Administration Annual Report 2006-2009

ការប្រឹងប្រែងមួយផ្សេងទៀត គឺផ្តោតលើការរៀបចំកំណត់ព្រំប្រទល់ឡូត៍នេសាទ និងព្រៃលិចទឹក ។ សកម្មភាពនេះនឹងជួយកាត់បន្ថយទំនាស់រវាងម្ចាស់ឡូត៍នេសាទ រវាងអ្នកស្រុកអ្នកភូមិ ជាមួយនឹងសមត្ថកិច្ចជលផល ។

គ.សហគមន៍នេសាទ

នៅចុងឆ្នាំ២០០០ មានចំនួនសហគន៍នេសាទតិចតួចណាស់នៅតាមខេត្តដូចជាស្ទឹងត្រែង ក្រចេះ ស្វាយរៀង និងសៀមរាប ។ សហគមន៍នេសាទទាំងនោះត្រូវបានរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាល ដោយផ្អែកទៅលើបទពិសោធន៍ដែលគេមាននៅតាមប្រទេសជិតខាង ហើយពុំបានធ្វើតាមផែនការនយោបាយអ្វីមួយពិតប្រាកដឡើយ ។

ក្រោយពីរដ្ឋាភិបាលបានប្រកាសកែទម្រង់វិស័យជលផលមក ចាប់តាំងពីចុងឆ្នាំ២០០០ ការបង្កើតសហគមន៍នេសាទត្រូវបានរីកដុះដាលពេសពេញប្រទេស ។ ទំហំដែននេសាទដែលបានលុប និងកាត់បន្ថយផ្ទៃក្រឡាឡូត៍នេសាទចំនួនជាង ៥៦% សម្រាប់ប្រជាពលរដ្ឋ ធ្វើនេសាទជាលក្ខណៈគ្រួសារ ដោយបានរៀបចំជាសហគមន៍នេសាទ ។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលបានបង្កើតកម្រង លិខិតបទដ្ឋានគតិយុត្តិទាក់ទងនឹងសហគន៍នេសាទសម្រាប់គ្រប់គ្រង និងអភិវឌ្ឍឲ្យបានរីតតែប្រសើរឡើង។

ចាប់តាំងពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៩ សហគមន៍នេសាទដែលបានបង្កើតឡើងមានចំនួន ៤៦៩ គាំទ្រដោយគ្រួសារចំនួន ១២៦,៤០០ រួមមានសមាជិកទាំងអស់២៧៧,០៥៤ ។ ក្នុងនោះសហគមន៍នេសាទទឹកសាបមាន ៤៣៤ និង ត្រីសមុទ្រ ៣៥ ។ លើសពីនោះទៅទៀតរដ្ឋបាលជលផលបានបង្កើតក្រុមធនាគារក្តាម (Crab banking Group) ចំនួន ១០ ដែលមានបែរចំនួន ២៦ និង១០ក្រុមទៀតមានបែរចំនួន ២០ នៅខេត្តកែប ។ ការបង្កើត ក្រុមធនាគារក្តាមនេះ មានគោលដៅលើកទឹកចិត្តឈ្មួញលក់ក្តាមឱ្យខិតខំប្រមូលក្តាមញីដែលមានពងមកដាក់ចិញ្ចឹមក្នុងបែរ ដើម្បីផ្តល់ក្តាមទៅអនាគត ។ លទ្ធផលនៃការប្រឹងប្រែង គឺចាប់បានក្តាមញីចំនួន ១៩,៧២៤ (៨,១២៨ក្បាលនៅកោះកុង ៥,៥៤៧នៅក្រុងព្រះសីហនុ និង៦,០៤៩ នៅ កំពត) ។ បើទោះជាមានការប្រឹងប្រែង យ៉ាងនេះក៏ដោយ សភាពទន់ខ្សោយនៅតែមានខ្លះៗ ដោយសារការខ្វះខាតនៃការអប់រំ ការតាមសង្កេត និងការចែកចាយព័ត៌មានដល់អ្នកនេសាទ ពីសំណាក់រដ្ឋបាលជលផល និងការគ្រប់គ្រងសហគមន៍នៅទន់ខ្សោយពីសំណាក់អ្នករៀបចំដំណើរការសហគមន៍ ។ តែទោះបីជាយ៉ាងនេះក៏ដោយ រដ្ឋបាលជលផលក៏នៅតែបន្តការប្រឹង ប្រែងរបស់

ខ្លួនដើម្បីកែច្នៃរបៀបគ្រប់គ្រងសហគមន៍ឱ្យរឹតតែមានប្រសិទ្ធភាពតាមរយៈការបង្រៀន និង តាមដានសង្កេតជារឿយៗចំពោះសកម្មភាពរបស់អ្នកគ្រប់គ្រងសហគមន៍នៅមូលដ្ឋាន ។

## III. បញ្ហាប្រឈម និងឧបសគ្គ

រដ្ឋបាលជលផលបានប្រឹងប្រែងយ៉ាងសកម្មក្នុងការគ្រប់គ្រងធនធានជលផលឱ្យមាន ចីរភាពធានាសន្តិសុខម្ហូបអាហារ និងបង្កើតឱ្យមានសមភាពក្នុងការប្រកបអាជីវកម្មនេសាទ ។ ដើម្បីបំពេញតួនាទីនេះរដ្ឋបាលជលផលបានជួបប្រទះនឹងបញ្ហាពាក់ព័ន្ធជាច្រើន ៖

### ១-ការនេសាទហួសកម្រិត

នាពេលបច្ចុប្បន្ននេះបញ្ហានេសាទហួសកម្រិតជាបញ្ហាចម្បង ។ ទម្ងន់ត្រីដែលអាចចាប់ បានរបស់អ្នកនេសាទម្នាក់ៗបានចុះថយជាលំដាប់ ពិសេសនៅទន្លេឈ្លប ។ ទម្ងន់ត្រីបានចុះពី ៣៨៧ គីឡូក្រាមក្នុង១ឆ្នាំសម្រាប់អ្នកនេសាទនៅឆ្នាំ ១៩៨០ មក១៩២គីឡូក្រាមនៅឆ្នាំ១៩៩៥ និងចុះមកដល់១១៦គីឡូក្រាមនៅឆ្នាំ ២០០៨។

### ២-កំណើនប្រជាពលរដ្ឋ

នៅក្នុងតំបន់ទន្លេសាប ចំនួនអ្នកនេសាទបានកើនឡើងជាលំដាប់ ។ នៅឆ្នាំ ១៩៨០ មានអ្នកនេសាទចំនួន ០,៣៦លាននាក់ នៅឆ្នាំ១៩៩៥ មាន១,២លាននាក់ និងនៅឆ្នាំ២០០៨ មាន១,៥លាននាក់ ។ កំណើន អ្នកនេសាទក៏បានធ្វើឱ្យចំនួនឧបករណ៍នេសាទកើនឡើង ហើយរឹតតែមានបច្ចេកទេសខ្ពស់ផងដែរ។ ជាមួយគ្នានេះ ចំនួនប្រជាពលរដ្ឋក្នុងប្រទេសក៏បាន កើនឡើងជាលំដាប់តាមអត្រា ១,៥៤%ក្នុងមួយឆ្នាំ ។ ចាប់ផ្តើមពីឆ្នាំ ២០១០មក ប្រទេសកម្ពុជា មានប្រជាពលរដ្ឋសរុបចំនួន១៥លាននាក់ ។ នេះមានន័យថា ចំនួនត្រីត្រូវតែចាប់បន្ថែម ដើម្បី បម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។

### ៣-ឧបករណ៍ខុសច្បាប់

ការប្រើប្រាស់ឧបករណ៍ចាប់ត្រីខុសច្បាប់មានពាសពេញទាំងប្រទេស ។ ឧបករណ៍ទាំង នោះបានបំផ្លិចបំផ្លាញធនធានត្រីទាំងតូចទាំងធំ ដូចជាការប្រើឧបករណ៍ឆក់ត្រី ការប្រើអួន មង សំណាញ់ក្រឡាល្អិត និងការប្រើរបាំងស្បៃមុង និងលូស្បៃមុង។

៤-ការបាត់បង់ទីជម្រករបស់ត្រី

ក្នុងមួយឆ្នាំៗ ព្រៃលិចទឹកជាច្រើនហិកតាត្រូវបានប្រជាពលរដ្ឋកាប់ឆ្ការដើម្បីយកអុសដុត និងដើម្បីប្រកបរបរកសិកម្ម។ ការប្រើជីរ និងថ្នាំសម្លាប់សត្វល្អិតបានកើនឡើងជាលំដាប់។ នៅឆ្នាំ ២០០០ គេបានប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត អស់ ១,៣លានលីត្រ ក្នុងតំបន់ទន្លេសាប ។ ការសាងសង់ទំនប់ទឹក សាងសង់អាងទឹកធ្វើឱ្យបាត់បង់ព្រៃលិចទឹកបណ្តាលពីការធ្វើស្រែប្រាំង ដែលនាំឲ្យដីហូរច្រោះ និងធ្វើឱ្យទឹកទន្លេសាបរាក់ជាលំដាប់។ ជាការល្អដែរ ដែលនៅពេលថ្មីៗរាជរដ្ឋាភិបាលបានបញ្ជាឱ្យបំផ្លាញទំនប់ទឹក និងបណ្តាញអាងទឹកទាំងឡាយណាដែលខុសច្បាប់។

៥-វារីអគ្គីសនី

គេបានរៀបចំគម្រោងសាងសង់ទំនប់ជាច្រើនតាមដងទន្លេ និងដៃទន្លេមេគង្គចាប់តាំងពីឆ្នាំ១៩៥០ និង ១៩៦០មកម្ល៉េះ តែគម្រោងទាំងនេះត្រូវបានផ្អាកជាបណ្តោះអាសន្នដោយសារសង្គ្រាមក្នុងតំបន់ ។

នៅពេលនេះដោយសារមានបំណងអភិវឌ្ឍន៍សេដ្ឋកិច្ច រដ្ឋាភិបាលនៃប្រទេស នីមួយៗតាមដងទន្លេមេគង្គបានស្វះស្វែងរិះរកវិធីសាស្ត្រណាដែលអាចបង្កើតអគ្គិសនីមានថ្លៃថោកហើយមានចំនួនគ្រប់គ្រាន់ផង ។ ដូច្នេះថាមពលវារីអគ្គីសនីជាជម្រើសចម្បងរបស់គេ ។ ហើយចាប់តាំងពីឆ្នាំ២០០៦មក ជម្រើសនេះត្រូវបានអនុវត្តយ៉ាងសកម្ម ។ ទំនប់វារីអគ្គីសនីចំនួន៧៧នៅតាមដៃទន្លេមេគង្គត្រូវបានគេយល់ព្រមឱ្យសាងសង់ហើយ។ លើសពីនេះទៀត វិនិយោគិនមកពីប្រទេសចិនប្រជាមានិត ម៉ាឡេស៊ី និងវៀតណាម បានទទួលការអនុញ្ញាតឱ្យធ្វើសំណើដើម្បីសាងទំនប់វារីអគ្គីសនីចំនួន១១ទៀតលើទន្លេមេគង្គតែម្តង:

-ទំនប់វារីអគ្គីសនី៩នៅប្រទេសឡាវ ទំនប់វារីអគ្គីសនីទី១ គឺសាយ៉ាបុរី អាចផ្តល់ថាមពល ១២៦០ មេហ្គាវ៉ាត់ ហើយត្រូវការពេលវេលា៨ឆ្នាំដើម្បីសាងសង់ ។ នៅពេលនេះគម្រោងទំនប់នេះត្រូវបានទទួលការរិះគន់យ៉ាងខ្លាំងពីរដ្ឋាភិបាល ប្រទេសផ្សេងៗ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិជាច្រើន ។

-ទំនប់វារីអគ្គីសនី២នៅព្រះរាជាណាចក្រកម្ពុជា ។ ទំនប់ទាំងពីរនេះនៅក្រោមគេបំផុតលើទន្លេមេគង្គ ។ តាមបច្ចេកទេស ទំនប់នេះនឹងបង្កើតឱ្យមានផលអវិជ្ជមានយ៉ាងខ្លាំង ។ ព្រះរាជាណាចក្រកម្ពុជាអាចទទួលការបាត់បង់ផលត្រីប្រហែល ២១០,០០០តោនក្នុងមួយឆ្នាំៗ

ថ្វីត្បិតតែទំនប់នេះអាចផ្តល់ផលវិជ្ជមានផងដែរ ដូចជាតម្លៃអគ្គិសនីថោក សម្រាប់អភិវឌ្ឍន៍ឧស្សាហកម្ម និងអភិវឌ្ឍន៍ទូទៅក្នុងប្រទេស ។

តាមការប៉ាន់ស្មានរបស់គណៈកម្មាធិការទន្លេមេគង្គ ៖

-នៅឆ្នាំ២០១៥នឹងមានទំនប់៩៥អាចចាប់ផ្តើមមានសកម្មភាពតាមទន្លេមេគង្គ

-ដល់ឆ្នាំ២០៣០នឹងមានទំនប់ទាំងអស់៧៧អាចចាប់ផ្តើមមានសកម្មភាព ។

-ទន្លេមេគង្គផ្នែកខាងក្រោមអាចផ្តល់ផលត្រីក្នុងមួយឆ្នាំៗបានចំនួនជាង២លានតោន មានតម្លៃ២០០០លានដុល្លារ ។ ប្រសិនបើទំនប់វារីអគ្គិសនីទាំង៧៧ និងទំនប់វារីអគ្គិសនីទាំង ១១តាមដងទន្លេមេគង្គត្រូវបានសាងសង់តាមគម្រោង ការបាត់បង់ផលត្រីអាចមានកម្រិតខ្ពស់ដល់៨៨០,០០០តោនក្នុងមួយឆ្នាំ ។

៦-កង្វះមន្ទីរពិសោធន៍

រហូតមកដល់ពេលនេះ ពុំទាន់មានមន្ទីរពិសោធន៍ណាមួយដែលមានលក្ខណៈពេញលេញដើម្បីពិនិត្យមេរោគ ជម្ងឺផ្សេងៗ និងកាកសំណល់គីមីដែលមានសេសសល់ក្នុងត្រីនៅឡើយទេ ។ កង្វះខាតនេះទប់ស្កាត់ពុំឱ្យការអភិវឌ្ឍន៍ក្នុងការបង្កើនផលត្រី និងពុំធ្វើឱ្យការនាំចេញត្រីទៅបរទេសបានរីកចម្រើនឡើយ ។

៧-កង្វះអ្នកឯកទេស និងបច្ចេកទេស

ថ្វីត្បិតតែរដ្ឋបាលជលផលមានបុគ្គលិកជាង ១០០០នាក់ក៏ដោយ ចំនួននេះមិនទាន់គ្រប់គ្រាន់នៅឡើយ សម្រាប់បង្ក្រាបបទល្មើសជលផល និងពង្រីកវារីវប្បកម្ម ។ ជាពិសេសមានការខ្វះខាតយ៉ាងខ្លាំងចំពោះអ្នកឯកទេសខាង ស្រាវជ្រាវបច្ចេកទេស វារីវប្បកម្ម និងឯកទេសជំងឺត្រី អនាម័យ គុណភាព និងសុវត្ថិភាពផលិតផលជលផល។

៨-កង្វះទំនាក់ទំនងរវាងអ្នកប្រកបមុខរបរនេសាទ

អ្នកចិញ្ចឹមត្រី និងអ្នកទិញត្រី ព្រមទាំងអាជីវករកែច្នៃពុំទាន់មានទំនាក់ទំនងគ្នាល្អនៅឡើយ ។ កង្វះខាតនេះបានធ្វើឱ្យមានកង្វះខាតខាងការជួយអប់រំលើបញ្ហាបច្ចេកទេសដែលជួយបង្កឱ្យចេះប្រើប្រាស់វត្ថុធាតុដើមក្នុងការចិញ្ចឹមត្រីឱ្យមានប្រសិទ្ធភាព ជំនួយហិរញ្ញវត្ថុ និងជួយឱ្យមានការយល់ដឹងពីរបៀបរបបការនាំចេញទៅបរទេស ។

## IV.**ភាពលទ្ធភាព**

យើងបានឃើញច្បាស់លាស់ហើយថា រដ្ឋបាលជលផលបានជួបប្រទះនឹងឧបសគ្គព្រមទាំងបញ្ហាយ៉ាងច្រើន ។ រដ្ឋបាលជលផលអាចមានលទ្ធភាព នឹងទទួលជោគជ័យបានលើឧបសគ្គទាំងនោះ ប្រសិនបើមានការគាំទ្រយ៉ាងសកម្ម និងគ្រប់គ្រាន់ពីសំណាក់រាជរដ្ឋាភិបាល និងក្រុមដៃគូអភិវឌ្ឍន៍ ។

### ១-ការបង្ក្រាបបទល្មើស

រដ្ឋបាលជលផលបានចងក្រងលិខិតបទដ្ឋានច្បាប់សម្រាប់គ្រប់គ្រងធនធានជលផលជាច្រើនយ៉ាងរួចស្រេចបាច់ហើយ ។ ការអនុវត្តច្បាប់ទាំងនោះ ដែលទាក់ទងនឹងការនេសាទហួសកម្រិត ការប្រើប្រាស់ឧបករណ៍ខុសច្បាប់ ការចាប់ត្រីដោយខុសលក្ខណៈបច្ចេកទេស ការចាប់ត្រីខុសរដូវ ការកាប់ឆ្ការព្រៃលិចទឹកខុសច្បាប់ អាចនឹងធ្វើឱ្យរឹតតែបានប្រសើរឡើង ប្រសិនបើមានការគាំទ្រទាំងថវិការ សម្ភារៈ និងធនធានមនុស្សយ៉ាងគ្រប់គ្រាន់ និងទាន់ពេលវេលា ។

### ២-បង្កើនចំនួនកន្លែងភ្ញាស់កូនត្រីពូជ

វិធានការមានជាច្រើនដើម្បីបង្កើនធនធាននេសាទសម្រាប់ផ្គត់ផ្គង់សេចក្ដីត្រូវការក្នុងស្រុក និងនាំចេញទៅបរទេសតាមរយៈការបង្កើនចំនួនកន្លែងភ្ញាស់កូនត្រីពូជសម្រាប់ចិញ្ចឹម និងលែងតាមទន្លេបឹងបួរ និងតាមរយៈ វារីវប្បកម្ម ។ នៅពេលបច្ចុប្បន្នមានកន្លែងភ្ញាស់កូនត្រីពូជចំនួនជាង ២៨០កន្លែងដែលផ្គត់ផ្គង់កូនត្រីប្រហែល១១០លាន កូនសម្រាប់បង្កើនធនធានត្រីទៅអនាគត (តារាង១៣)។

តារាង១៣. ចំនួនកន្លែងភ្ញាស់កូនត្រី និងចំនួនកូនត្រី ២០០៦-២០០៩ (ជា១០០០ក្បាល)

| | ២០០៦ | | ២០០៨ | | ២០០៩ | |
|---|---|---|---|---|---|---|
| ប្រភេទ | កន្លែងភ្ញាស់ | កូនត្រី | កន្លែងភ្ញាស់ | កូនត្រី | កន្លែងភ្ញាស់ | កូនត្រី |
| ត្រីទឹកសាប | 69 | 20,485 | 145 | 32,058 | 166 | 56,750 |
| ត្រីសមុទ្រ | 1 | 850 | 24 | 5,135 | 29 | 13,000 |
| សរុប | 70 | 21,335 | 169 | 37,193 | 195 | 69,750 |

ប្រភព Fisheries Administration Annual Report 2006,2008,2009

ចំនួនកន្លែងភ្ញាស់កូនត្រីទឹកសាបមានជាច្រើននៅជុំវិញទន្លេសាប ជុំវិញក្រុងភ្នំពេញ និងក្នុងខេត្តកណ្តាល។ ចំណែកឯទឹកប្រៃវិញមានជាច្រើននៅខេត្តកំពត ។ បើមានការលើកទឹកចិត្តបន្ថែមឱ្យមានការចូលរួមពីសំណាក់អ្នកនេសាទលក្ខណៈគ្រួសារ និងលក្ខណៈសិប្បកម្មនិងឯកជនផ្សេងទៀត ការបង្កើនចំនួន កន្លែងភ្ញាស់ត្រី និងរឹតតែបានជោគជ័យ តែរដ្ឋបាលជលផលគួរតែពង្រឹងការផ្តល់បច្ចេកទេសរបស់ខ្លួនដោយសហការជាមួយដៃគូអភិវឌ្ឍន៍ផងដែរ។

៣-ពង្រឹងសហគមន៍នេសាទ

មានសហគមន៍នេសាទចំនួនជាង ៤០០កំពុងដំណើរការ ។ ឯកសារទាក់ទងនឹងការណែនាំបង្កើត និង គ្រប់គ្រងសហគមន៍ត្រូវបានរដ្ឋបាលជលផលចែកចាយរួចហើយ តែដំណើរការរបស់សហគមន៍ខ្លះៗនៅតែមានការរអាក់រអួលដោយខ្វះការណែនាំ និងតាមដានការអនុវត្តពីសំណាក់រដ្ឋបាលជលផល និងអង្គការមិនមែនរដ្ឋាភិបាល ។ បន្ថែមការណែនាំដល់សហគមន៍នេសាទ និងបន្ថែមការតាមដានការអនុវត្តនៅមូលដ្ឋាន នឹងធ្វើឱ្យមានការរីកចម្រើនក្នុងការបង្កើនផលនេសាទទៅអនាគត ។

៤-វារីវប្បកម្ម

សម្រាប់គ្រួសារដែលបានអនុវត្តវារីវប្បកម្ម ផលត្រីដែលទទួលបានគឺប្រហាក់ប្រហែលនឹងមានប្រាក់ដាក់ក្នុងធនាគារ ។ ការចិញ្ចឹមត្រី នឹងធ្វើឱ្យត្រីធំធាត់ហើយអាចបង្កើតកូនបន្តពូជទៀត ។ កាលណាម្ចាស់ចិញ្ចឹមត្រូវការប្រាក់កាសគេក៏ចាប់ត្រីយកទៅលក់ជាការស្រេច ។

ការចិញ្ចឹមត្រីបានផ្តល់ផលតិចជាង១០%នៃតម្រូវការទីផ្សារប៉ុណ្ណោះ ដូច្នេះឱកាសសម្រាប់ ពង្រីកវារីវប្បកម្មនៅមានទូលំទូលាយណាស់ ។

ការផ្តល់កូនត្រីឱ្យកសិករដើម្បីយកទៅចិញ្ចឹម ផ្តល់ប្រាក់កម្ចីដោយការប្រាក់ទាប ផ្តល់ជំនួយបច្ចេកទេសក្នុងការចិញ្ចឹមត្រី ថែទាំសុខភាពត្រី និងព្យាបាលជំងឺត្រី នឹងលើកទឹកចិត្តកសិករឱ្យចូលរួមយ៉ាងសកម្មក្នុងវិស័យនេះនិងធ្វើឱ្យវារីវប្បកម្មមានការដុះដាលយ៉ាងឆាប់រហ័ស ។

៥-ពង្រឹងសមត្ថភាពបុគ្គលិករដ្ឋបាលជលផល

រាជរដ្ឋាភិបាលបានឲ្យបង្កើតសហគមន៍នេសាទជាចម្បងក្នុងការកែទម្រង់នយោបាយជលផល ពីព្រោះវាជាមធ្យោបាយដែលពុំត្រូវការថវិកាច្រើនហើយបានជួយផ្ទាល់ដល់ប្រជា

ពលរដ្ឋក្រីក្រផង ។ នយោបាយនេះតម្រូវ ឱ្យមានអ្នកឯកទេសខាងសហគមន៍នេសាទ និងវារីវប្បកម្មគ្រប់គ្រាន់តាមរយៈវិធីកម្មសិក្សាក្នុងស្រុក និងបរទេស។ ជាពិសេសទៅទៀតអ្នកឯកទេសខាងជំងឺត្រីមានការខ្វះខាតយ៉ាងច្រើន ហើយត្រូវការជាបន្ទាន់ ។ ទន្ទឹមនឹងនោះរដ្ឋបាលជលផលក៏ត្រូវការមន្ទីរពិសោធន៍ថ្នាក់ជាតិ ដែលមានលទ្ធភាពគ្រប់គ្រាន់ក្នុងការវិភាគរកជំងឺត្រី និងមេរោគផ្សេងៗទៀត ដែលបង្កឲ្យមានជំងឺត្រីជាដើម។ តម្រូវការទាំងនេះទាមទារឱ្យមានកិច្ចសហការពីអង្គការមិនមែនរដ្ឋាភិបាល ជាតិនិងអង្គការអន្តរជាតិផងដែរ ។

៦-សម្របសម្រួលរបៀបធ្វើជំនួញ

រាជរដ្ឋាភិបាលពុំទាន់បានរៀបចំការចាត់លំដាប់ថ្នាក់ផលិតផលត្រីឱ្យបានច្បាស់លាស់ និងអាជ្ញាធរដែលអាចចេញវិញ្ញាបណ្ណប័ត្របញ្ជាក់ពីសុវត្ថិភាពចំណីអាហារ( SPS )ដែលមានលក្ខណៈអន្តរជាតិនៅឡើយ ដោយហេតុគ្មានបុគ្គលិកគ្រប់គ្រាន់ ថវិកា និងមន្ទីរពិសោធន៍ត្រឹមត្រូវតាមស្តង់ដារអន្តរជាតិ ។ កង្វះខាតនេះបានផ្តល់ឱកាសជូនរាជរដ្ឋាភិបាលដើម្បីធ្វើសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិផ្សេងៗជាដៃគូអភិវឌ្ឍន៍។

បើកិច្ចសហការនេះអាចសម្រេចបាន ព្រះរាជាណាចក្រកម្ពុជាអាចបង្កើនបរិមាណជលផលដែលអាចនាំចេញបាន ហើយនឹងពង្រីកទីផ្សាររបស់ខ្លួនជាវិជ្ជមានផង ។

៧-បញ្ហាទាក់ទងនឹងដំណើរការក្រោយពីចាប់បានត្រី

ការនេសាទត្រីទឹកសាបប្រព្រឹត្តទៅតាមរដូវ ដូច្នេះការប្រើប្រាស់ផលនេសាទក៏តម្រូវទៅតាមរបៀបនេះដែរ គឺថាត្រីខ្លះត្រូវប្រើប្រាស់ភ្លាមៗ ត្រីខ្លះទៀតត្រូវការកែច្នៃសម្រាប់ប្រើប្រាស់នៅពេលក្រោយ ឬនាំចេញ។ សព្វថ្ងៃនេះ អ្នកនេសាទត្រី និងឈ្មួញលក់ដូរផលត្រីបានទទួលការខាតបង់យ៉ាងច្រើនទាំងតម្លៃ ទាំងបរិមាណ ដោយសារវិស័យនេះ គ្មានកន្លែងស្តុកត្រីត្រឹមត្រូវ គ្មានកន្លែងកែច្នៃត្រីគ្រប់គ្រាន់ ជាពិសេសចំពោះត្រីសមុទ្រ ។ ការធ្វើ ឱ្យប្រសើរឡើងនូវការកែច្នៃត្រី ការដឹកជញ្ជូន និងទីកន្លែងស្តុកត្រី នឹងធ្វើឱ្យទិន្នផលរឹតតែកើនឡើង បង្កើនការងារជូនប្រជាពលរដ្ឋ និងកំណើនប្រាក់ចំណូល ។ ការកែលម្អរចនាសម្ព័ន្ធ និងទីកន្លែងទាំងនោះ នឹងបង្កលក្ខណៈងាយស្រួលឱ្យឈ្មួញ មានលទ្ធភាពអាចនាំចេញត្រីទៅបរទេសដោយផ្ទាល់ ដោយពុំចាំបាច់តាមរយៈប្រទេសជិតខាងដែលទិញផលត្រីពីខ្មែរយើងតាមតម្លៃយ៉ាងថោក នោះទេ ។

ក្នុងកាលៈទេសៈនេះ កត្តាគម្រាមកំហែងជាចម្បងលើការអភិវឌ្ឍវិស័យជលផលនៅព្រះរាជាណាចក្រកម្ពុជា គឺភាពខ្វះខាតការគាំទ្រទាំងផ្នែកថវិកា និងបច្ចេកទេសដល់រដ្ឋបាលជលផលសម្រាប់ៈ

-ធ្វើការអប់រំ និងតាមដានការគ្រប់គ្រងសហគមន៍នេសាទ

-ពង្រឹងសមត្ថភាពបុគ្គលិករដ្ឋបាលជលផលសម្រាប់ជួយណែនាំសមាជិកសហគមន៍នេសាទក្នុងការចិញ្ចឹម និងថែទាំត្រីកុំឱ្យមានជំងឺផ្សេងៗ

-បង្កើតមន្ទីរពិសោធន៍មួយដែលមានលក្ខណៈអន្តរជាតិ និងការិយាល័យពេញច្បាប់មួយដែលមានសិទ្ធចេញវិញ្ញាបណ្ណប័ត្របញ្ជាក់ពីសុវត្ថិភាពចំណីអាហារ(SPS )បាន ។

## VI. **អនុសាសន៍**

ព្រះរាជាណាចក្រកម្ពុជាមានសក្តានុពលដើម្បីបង្កើនបរិមាណជលផលសម្រាប់បំពេញសេចក្តីត្រូវការក្នុងស្រុកបាន ហើយនឹងបង្កើនការនាំចេញទៀតផង ។ កង្វះខាតសម្រាប់សម្រេចនូវគោលបំណងនេះ គឺការណែនាំជាក់ស្តែង ពីសំណាក់រដ្ឋបាលជលផលដល់ប្រជាពលរដ្ឋអ្នកនេសាទ និងការចូលរួមយ៉ាងសកម្មពីដៃគូអភិវឌ្ឍន៍ជាតិ និង អន្តរជាតិក្នុងការពង្រឹងសមត្ថភាពបុគ្គលិករដ្ឋបាលជលផល និងសមាជិកសហគមន៍នេសាទ និងការផ្តល់មន្ទីរពិសោធន៍ដែលមានលក្ខណៈអន្តរជាតិ ។

កាលណាដៃគូទាំងអស់បានចូលរួមសហការគ្នា គោលដៅចម្បងសម្រាប់គ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព នឹងអាចសម្រេចបានដោយជោគជ័យ ។

30/08/11

**បណ្ឌិត ស៊ិន ម៉េងស្រ៊ុន**

ប្រធានអនុក្រុមស្រាវជ្រាវសេដ្ឋកិច្ចកសិកម្ម

ECOSOCC

## References


1-Cambodia Daily, (Feb 12-13, 2011) "The meeting in Peril"
2-CDRI (2002). Cambodia Annual Development Review 2002.
3-CDRI (2007). Cambodia Annual Development Review 2006-2007.
4-CDRI (2008). Cambodia Annual Development Review 2007-2008.
5-CDRI (2009). Cambodia Annual Development Review 2008-2009.
6-CDRI (2010). Cambodia Annual Development Review 2009-2010.
7-Fisheries Administration (2006). Annual Report 2006
8-Fisheries Administration (2007). Annual Report 2007
9-Fisheries Administration (2008). Annual Report 2008
10-Fisheries Administration (2009). Annual Report 2009
11-Fisheries Administration (2008). The Compilation of Legal instruments related to Community Fisheries in the Kingdom of Cambodia
12-Fisheries Administration (2010) "Draft strategy for the development of Fisheries 2010-2019"
13-Fisheries Administration (2010) "Fisheries in Cambodia. Current Status, Key issues, Direction" , Power Point Presentation.
14-Fisheries Administration (2007) "Gender mainstreaming Policy and Strategy in The Fisheries Sector"
15-Hang Chuon Naron (2009) Cambodian Economy Charting the course of a Brighter Future.
16-MAFF(2008). Annul Report 2007-2008
17-MAFF(2009). Annul Report 2008-2009
18-MAFF(2010). Annul Report 2009-2010
19-MAFF(2011). Fisheries Law
20-Ministry of Commerce (1996). Cambodia Business & Investment Handbook
21-Ministry of Commerce (2007). Cambodia's Updated Trade Integration Strategy. DTIS
22-National Institute of Statistics (2005). Statistical Yearbook Cambodia
23-National Institute of Statistics (2008). Statistical Yearbook Cambodia
24-Unanimous, August September 2009 "Achieving Food Security in Cambodia through Improved Agriculture and Environmental Sustainability"
25-www.worlfishcenter.org
26-www.fao.org.un
27-www.stats.maff.gov.kh


## MEETING

On Dec 10, 2010, a meeting was arranged between Agricultural subcommittee of ECOSOCC and Deputy of Fisheries Administration and his chiefs of various departments. Power point presentation was made by Deputy Director and his staff providing very important information on various issues int fisheries.

Additional published documents were given to each member of the sub-committee. Many thanks to the Fisheries Administration for such level of cooperation.